សូមគោរពអ្នកដាក់ពាក្យសុំ SNAP

ការដាក់ពាក្យស្នើសុំ ឬទទួលកម្មវិធី SNAP **<u>មិន</u>** មិនធ្វើឱ្យអ្នកក្លាយមនុស្សក្នុងបន្ទុករដ្ឋ ហើយនឹង **<u>មិន</u>** ត្រូវបានពិចារណាក្នុងការកំណត់បន្ទុករដ្ឋនោះដែរ។ ការដាក់ពាក្យស្នើសុំ ឬទទួលកម្មវិធី SNAP នឹង **<u>មិន</u>** ប៉ះពាល់ដល់សមត្ថភាពរបស់អ្នកក្នុងការៈ

- **បន្តនៅសហរដ្ឋអាមេរិក**
- **ទទួលបាន Green Card (ប័ណ្ណបៃតង)/ឋានៈនិវាសនជនអចិន្ត្រៃយ៍ស្របច្បាប់**
- **រក្សា Green Card (ប័ណ្ណបៃតង)/ឋានៈនិវាសនជនអចិន្ត្រៃយ៍ស្របច្បាប់ ឬ**
- **ក្លាយជាពលរដ្ឋ U.S.។**

អ្នកក៏អាចដាក់ពាក្យស្នើសុំកម្មវិធី SNAP ក្នុងនាមជនអន្តោប្រវេសន៍ ឬពលរដ្ឋ U.S. ដែលមានសិទ្ធិក្នុងគ្រួសាររបស់អ្នក បើទោះបីជាអ្នកមិនចង់ស្នើសុំអត្ថប្រយោជន៍សម្រាប់ខ្លួនអ្នក ដោយមិនប៉ះពាល់ដល់ឋានៈអន្តោប្រវេសន៍របស់អ្នក ឬពួកគេក៏ដោយ។ ឧទាហរណ៍ ប្រសិនបើឪពុកម្តាយមិនមានសិទ្ធិទទួលបានកម្មវិធី SNAP ដោយសារតែឋានៈអន្តោប្រវេសន៍របស់ពួកគេ ពួកគេនៅតែអាចដាក់ពាក្យសុំសម្រាប់កូនរបស់ពួកគេដែលមានសិទ្ធិបានដដែល។ ការិយាល័យកម្មវិធី SNAP មិនត្រូវបានអនុញ្ញាតឱ្យសួររកឯកសារអន្តោប្រវេសន៍សម្រាប់អ្នកដែលមិនដាក់ពាក្យសុំដើម្បីទទួលបានអត្ថប្រយោជន៍ដោយខ្លួនឯងទេ។

បើអ្នកត្រូវការជំនួយស្បៀងអាហារ ហើយអ្នក ឬសមាជិកគ្រួសាររបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សូមដាក់ពាក្យសុំកម្មវិធី SNAP សម្រាប់ខ្លួនអ្នក ឬគ្រួសាររបស់អ្នក។ ធ្វើដើម្បីគ្រួសារអ្នក!

ចំពោះព័ត៌មានបន្ថែមទាក់ទងនឹងព័ត៌មានអន្តោប្រវេសន៍ទូទៅជាភាសាអង់គ្លេស ឬជាភាសាអេស្ប៉ាញ សូមទូរសព្ទទៅ USCIS តាមរយៈលេខ 1-800-375-5283។ ចំពោះព័ត៌មានទូទៅអំពីកម្មវិធី SNAP សូមទូរសព្ទទៅលេខ 1-800-221-5689 (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ឬ 202-720-2791 (ភាសាអង់គ្លេស និងភាសាអេស្ប៉ាញ) ដើម្បីភ្ជាប់ទៅបណ្តាញទូរសព្ទទាន់ហេតុការណ៍នៃកម្មវិធី SNAP នៅក្នុងរដ្ឋរបស់អ្នក។